អន្តរប្បវី
សម្លេងខ្មែរនៅបរទេស

# សឺង-ង៉ុកថាន់

# វត្តមានកងកម្លាំងពិសេសខ្មែរ

## សកម្មភាពលោកសឺង-ង៉ុកថាន់ ពីឆ្នាំ១៩៣០-១៩៧០

ដកស្រង់ចេញពីសៀវភៅរបស់លោក ថាច់-ខេមរិន្ទ

<u>កំណាត់របស់លី-ឌៀប</u> ៖

លោកសឹង-ង៉ុកថាន់, វិរ:បុរសជាតិរូបនេះបានបន្សល់ទុកនូវកេរដំណែលយ៉ាងច្រើនលើសលប់ នៅក្នុងក្រាំងសាវតានយោបាយខ្មែរសម័យទំនើប (Histoire contemporaine) ដើម្បីឲ្យកូនចៅជំនាន់ក្រោយបានសិក្សារៀនសូត្រ ។ ពេញមួយជីវិតរបស់លោក រហូតទល់ថ្ងៃស្លាប់នៅក្នុងគុកឃុំនទីក្រុងព្រៃនគរ គឺគ្មានអ្វីក្រៅអំពីធ្វើពលិកម្មបូជាចំពោះប្រជាជាតិខ្មែរ ដើម្បីខ្មែររួចផុតពីទុក្ខវេទនា ស្គាល់នូវពន្លឺលទ្ធិប្រជាធិបតេយ្យសេរីនិយម គេចចៀសផុតពីគ្រោះថ្នាក់នានាបង្កឡើងដោយពួកកុម្មុយនិស្តតែប៉ុណ្ណោះ ។

ការដឹកនាំ<ចលនាតស៊ូ>របស់លោក ពោរពេញទៅដោយភាពស្វិតស្វាញ បំរះននាល និងឈឺចាប់ខ្លោចផ្សារខ្លាំងណាស់ ។ លោកបានហែលឆ្លងកាត់គ្រោះថ្នាក់ ការភ័យរន្ធត់ ការព្រាត់ប្រាស់បែកបាក់គ្រួសារ ភាពក្រីក្រលំបាកវេទនាសព្វបែបយ៉ាង ព្រមទាំងអំពើនិរទេសខ្លួនចេញពីទឹកដីមាតុភូមិដ៏ជាទីស្នេហាផង ។

អ្នកស្រាវជ្រាវប្រវត្តិសាស្ត្រខ្មែរនិងបរទេសជាច្រើន បានទទួលស្គាល់លោក ជាអ្នកជាតិនិយមខ្មែរដ៏មុតស្រួចម្នាក់ ដែលគេមិនដែលបានជួបប្រទះ ។ លោក David P. Chandler បានចាប់ផ្តើមសៀវភៅ «សោកនាដកម្មនៃប្រវត្តិសាស្ត្រខ្មែរ» ( The Tragedy of Cambodian History)ដោយនិយាយអំពីជីវិតរបស់លោកសឹង-ង៉ុកថាន់ ។ នៅក្នុងសៀវភៅ «មនុស្សនិងវាសនា» (Hommes et Destins) លោក Bernard Hamel បានសរសេរបញ្ចូលឈ្មោះលោកសឹង-ង៉ុកថាន់ ទៅក្នុងចំណោមឈ្មោះវិរ:ជនល្បីល្បាញនៅក្នុងពិភពលោក ដែលគេគួរតែទទួលស្គាល់និងគួរតែចងចាំទុកជានិច្ច ។

នៅក្នុងឱកាសមហាសន្និបាតពិភពលោកលើកទី២នៃខ្មែរកម្ពុជាក្រោម ធ្វើឡើងនៅរដ្ឋធានីវ៉ាស៊ិនតោន កាលពីថ្ងៃទី១៩ សីហា ឆ្នាំ១៩៨៧ ខ្ញុំមានឱកាសបានជួបជាលើកដំបូងបង្អស់ ឧត្តមសេនីយ៍ Mike Healy ជាមេទ័ពអាមេរិកាំងដ៏ឆ្នើមម្នាក់នៅក្នុងសង្គ្រាមវៀតណាម ។ លោកមានកងកម្លាំងពិសេសរបស់លោកមួយ សុទ្ធជាទាហានជនជាតិខ្មែរកម្ពុជាក្រោម ។ ដោយការស្រឡាញ់យ៉ាងខ្លាំង លោកបានដាក់ឈ្មោះកងកម្លាំងនេះថា «Mike's Force» ។ លោកឧត្តមសេនីយ៍និយាយទាំងទឹកភ្នែករំលឹកឡើងវិញអំពីភាពស្និទ្ធស្នាលរបស់លោកជាមួយទាហានខ្មែរក្រោមទាំងអស់នោះ និងនិយាយអំពីលោកសឹង-ង៉ុកថាន់យ៉ាងដូច្នេះថា ៖

«អ្វីដែលខ្ញុំនឹងនិយាយទៅនេះ ចំពោះអ្នកខ្លះហាក់ដូចជាការថ្កោលទោសទៅលើនយោបាយរបស់អាមេរិកាំង និងបទពិសោធន៍ដ៏គួរឲ្យខ្មាស់អៀន ដែលយើងនិងកងកម្លាំងពិសេស ត្រូវនាំគ្នាចាកចេញពីទីនោះ ដោយបោះបង់ចោលមិត្តរបស់យើងនៅអាស៊ីអាគ្នេយ៍កាលពីឆ្នាំ១៩៧៣។ ខ្ញុំអាចនិយាយប្រាប់ទៅអស់លោកអ្នករាល់គ្នា ពីបទពិសោធន៍របស់ខ្ញុំឲ្យបានជ្រាបថា ខ្ញុំបានសំរក់ទឹកភ្នែកដោយក្តីអាម៉ាស់ជាច្រើនលើកច្រើនសារណាស់ ពីព្រោះការពាក់ព័ន្ធផ្ទាល់ខ្លួនរវាងខ្ញុំជាមួយ <ខ្មែរក្រោម>និង <កម្លាំងទ័ពខ្មែរសេរី> ដែលពួកគេមិនខ្លាច ហ៊ានដើបឈរជាមួយក្រុមអ្នកតស៊ូស៊ីវិល មាននៅពាសពេញទូទាំងដែនដីសណ្តរនៃអាស៊ីអាគ្នេយ៍ ហើយស្ថិតនៅកៀកស្មាជាមួយនឹងយើង ក្នុងពេលអ្នកដទៃខ្លះទៀតបានរត់ចោលយើងទាំងកំសាក...

ខ្ញុំនឹកឃើញការជួបសន្ទនាគ្នាជាមួយបណ្ឌិតសឹង-ង៉ុកថាន់ ក្នុងផ្ទះល្វែងដ៏តូចចង្អៀតមួយរបស់គាត់នៅព្រៃនគរ ពេលយើងរៀបចំបញ្ជូនជាលើកដំបូងបង្អស់ បីកងវរ:សេនាតូចទៅភ្នំពេញពីឡុងហៃ ។ គាត់និយាយប្រាប់ខ្ញុំថា «សម្បត្តិដ៏មានតម្លៃបំផុតនៃជាតិនិមួយៗនោះ គឺប្រជាពលរដ្ឋ ។ កិច្ចការពារដ៏ប្រសើរបំផុតចំពោះប្រជាពលរដ្ឋនៃប្រទេសនិមួយៗ ...គឺសេរីភាព ។ ហើយសេរីភាពនោះអាចធានាបាន ក៏ដោយសារភាពស្មើគ្នានៅក្រោមច្បាប់ប៉ុណ្ណោះ» ។ និយាយរួចគាត់ក៏ដកហូតសំណៅសរសេរដោយដៃជាអក្សរខ្មែរមួយរមូរចេញមក គឺអ្វីដែលគាត់ចង់លើកដំកើង ឲ្យទៅជារដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរ ។ គាត់មិនសូវចេះនិយាយភាសាអង់គ្លេសល្អប៉ុន្មានទេ តែគាត់និយាយប្រាប់ខ្ញុំថា គាត់បានប្រើប្រាស់រដ្ឋធម្មនុញ្ញអាមេរិកាំង ធ្វើជាគោលណែនាំ, មិនមែនរដ្ឋធម្មនុញ្ញអាល្លឺម៉ង់ទេ, មិនយកតាមរដ្ឋធម្មនុញ្ញអង់គ្លេសទេ... តែគឺរដ្ឋធម្មនុញ្ញអាមេរិកាំង ។ បណ្ឌិតសឹង-ង៉ុកថាន់និយាយប្រាប់ខ្ញុំថា ៖ គតិបណ្ឌិតកាលពីដើមដែលបានចែងទុកមកខ្លះៗនៅក្នុងពិភពលោក គឺនឹងធ្វើឲ្យប្រទេសនេះក្លាយទៅជាពន្លឺភ្លើងច្រោងនាំផ្លូវគេ ។ រួចគាត់បញ្ជាក់ថា ប្រទេសនោះគឺជាប្រទេសរបស់ភិនខ្ញុំ ។ ខ្ញុំមានមោទនភាពខ្លាំងណាស់ នៅពេលគាត់និយាយប្រាប់ខ្ញុំថា ៖ «ឥឡូវ, ជាការចាំបាច់ណាស់ដែលយើងត្រូវអប់រំពួកយុវជនក្មេងៗរបស់យើង ដើម្បីឲ្យបានយល់នូវអំណោយផលនៃសេរីភាព និងសិទ្ធិសំរេចវាសនាខ្លួនដោយខ្លួនឯង» ។ ប្រយោគចុងក្រោយបង្អស់មុនពេលយើងបញ្ជូនកងវរ:សេនាតូចទាំងបី ទៅកាន់ទីក្រុងភ្នំពេញគឺ ៖ «នៅក្នុងប្រទេសកម្ពុជា យើងត្រូវតែឲ្យមានយ៉ាងឆាប់រហ័សតាមដែលអាចធ្វើទៅបាន គឺសាធារណរដ្ឋរបស់ប្រជាពលរដ្ឋ, ដោយប្រជាពលរដ្ឋ និងដើម្បីប្រជាពលរដ្ឋ ហើយយើងនឹងអប់រំពួកគេ រួចប្រាប់ពួកគេឲ្យដឹងថា ទាំងអស់នេះជាទ្រព្យសម្បត្តិដ៏មានតម្លៃយ៉ាងខ្ពង់ខ្ពស់បំផុតដែលយើងគួរបូជាជីវិតដើម្បីឲ្យមាន» ។

❑

## លោកសឹង-ង៉ុកថាន់

### អតីតចលនាខ្មែរសេរី-អ្នកបង្កើតកម្លាំងពិសេស

លោក **សឹង-ង៉ុកថាន់**, ជាបុត្រទី៧នៃលោក **សឹង-ណៃវ** ដែលជាអភិបាលស្រុកព្រះត្រពាំង និងលោកស្រី **ថាច់-ធីតុប** ។ លោកកើតនៅថ្ងៃទី៧ ខែធ្នូ គ.ស.១៩០៩ ក្នុងសង្កាត់គគីរ (វិញធ្វឹង) ស្រុកព្រះត្រពាំង ។ ត្រកូលរបស់លោកប្រកបជីវភាពកសិកម្ម, មានភោគទ្រព្យគ្រប់គ្រាន់ល្មម ចិញ្ចឹមឲ្យលោកនិងបងប្អូនរបស់លោក អាចសិក្សាបានដល់ចប់ថ្នាក់មធ្យមសិក្សា ។

កាលនៅជាកុមារ លោកស្រីថាច់-ធីតុបជាមាតាបានយកទៅឲ្យនៅវត្តគគីរ, សិក្សាអក្សរខ្មែរ ។ ក្រោយមកឲ្យទៅរៀនសាលាបឋមសិក្សាជា

ន់ដំបូង ទៅទីរួមខេត្តព្រះត្រពាំង ហើយបានសិក្សាថ្នាក់បឋមសិក្សាបំពេញវិជ្ជានៅសាលា ឌូដា ដឺឡាក្រេ នាក្រុងភ្នំពេញ ។ លុះចប់បឋមសិក្សាបំពេញវិជ្ជាហើយ លោកបានទៅបន្តការសិក្សានៅរដ្ឋធានីព្រៃនគរ រួចទៅសិក្សានៅទីក្រុងប៉ារីស (ប្រទេសបារាំង) ដ៏រាបបានប្រឡងជាប់ស្ទាគប័ត្រភាគទី២ ហើយបន្តការសិក្សាខាងនីតិសាស្ត្របានមួយឆ្នាំ ទើបមានបញ្ជាឲ្យលោកត្រឡប់មកកាន់ទីក្រុងព្រៃនគរ ដើម្បីទទួលតំណែងជាលេខាធិការរងក្នុងរដ្ឋាភិបាលអាណានិគមបារាំង បន្ទាប់មកលោកបានត្រូវផ្លាស់មកធ្វើជាអ្នកបកប្រែភាសានៅភ្នំពេញ ។


លោកសឹង-ង៉ុកថាន់ (ឆ្នាំ១៩៧២)

អ្នកនាងកញ្ញា ហ្សៀយហ្សានកាបឺឡែស, នាយមន្ទីរពុទ្ធសាសនបណ្ឌិត្យ ដោយបានសង្កេតឃើញលោកសឹង-ង៉ុកថាន់ប្រកបដោយកិរិយាមារយាទត្រឹមត្រូវល្អ ធ្វើការយកចិត្តទុកដាក់ រហ័សរហួន, អ្នកនាងក៏សុំឲ្យរដ្ឋការចាត់លោកមកធ្វើជាអគ្គលេខាធិការនៅភ្នំពេញ ។

## ទាមទារឯករាជ្យពីបារាំង

( កំណត់ ៖ លោកសឹង-ង៉ុកថាញ់ បានធ្វើការទាមទារឯករាជ្យជូនស្រុកខ្មែរតាំងពីពេលស្តេចសីហនុទើបអាយុ២០ឆ្នាំ ពោលគឺពេលព្រះអង្គកំពុងពេញសប្បាយនឹងរាជបល្ល័ង្ក-រាជអំណាចម្ល៉េះ ) ។

លោកសឹង-ង៉ុកថាន់បានធ្វើការជាមួយនឹងព្រះសង្ឃ បញ្ញវ័ន្ត និងអ្នកស្នេហាជាតិទាំងអស់ ហើយបានបង្កើតសារពត៌មានមួយ សំរាប់ដាស់សតិកូនខ្មែរឈ្មោះ «**នគរវត្ត**» នៅក្នុងគ.ស.១៩៣៦ ។ សារពត៌មាននេះបានផ្សាយរហូតដល់គ.ស.១៩៤២ ទើបត្រូវបារាំងបិទលែងឲ្យចេញផ្សាយតទៅទៀត ។

ព្រះសង្ឃនិងអ្នកស្នេហាជាតិដែលចូលមករួមក្នុងឆាកនយោបាយជាមួយលោកសឹង-ង៉ុកថាន់ គឺសម្តេចព្រះសង្ឃរាជ **ជួន-ណាត**, ព្រះមហាមុនី **អ៊ុម-ស៊ូ**, ព្រះមហាព្រហ្មមុនី **អ៊ូ**, សម្តេចព្រះសង្ឃនាយក **ហួត-តាត**, ព្រះអាចារ្យ **ខៀវ-ជុំ**, លោកគ្រូ **ប៉ាង-ខាត់**, លោកអាចារ្យ **ហែម- ចៀវ**, លោក **ជុំ-មួង**, លោក **ស៊ឹម-វ៉ារ**, លោក **ប៊ុន-ចន្ទម៉ុល**, លោក **ប៉ាច -ឈឺន**, លោក **ប៊ូរ-ហ៊ាង**, លោក **ម៉ៅ-ហុង** ។ល។

លោកសឹង-ង៉ុកថាន់ជាអ្នកនយោបាយមួយរូប ដែលមានស្មារតីស្នេហាជាតិដ៏មុះមុត, លោកជាមេគំនិតនយោបាយខាងកាសែត <នគរវត្ត>។ លោកបានធ្វើសកម្មភាពយ៉ាងខ្លាំងក្លាប្រឆាំងនឹងបារាំង ហើយលោកជាមេដឹកនាំនៃការតស៊ូបដិវត្តន៍ ។ គួរកត់សំគាល់ថា កាលធ្វើការនៅពុទ្ធសាសនបណ្ឌិត្យនិងព្រះរាជបណ្ណាល័យ ក្នុងឋានៈជាអគ្គលេខាធិការ លោកសឹង-ង៉ុកថាន់បានឆ្លៀតក្នុងភារៈកិច្ចជាអ្នកចាត់ព្រះសង្ឃឲ្យនិមន្តទេសនាប្រដៅទាហាននោះ លោកក៏ជ្រើសតែព្រះសង្ឃណាដែលស្នេហាជាតិមុតមាំនិងបានរៀបហារ ឲ្យពន្យល់បញ្ចុះបញ្ចូលទាហានទាំងនោះ ឲ្យចេះស្រឡាញ់ជាតិក្រោកឡើងធ្វើការតស៊ូ ។ ព្រះសង្ឃអង្គដែលត្រូវបានកត់សំគាល់ថា បានបំពេញសកម្មភាពបែបនេះ គឺលោកអាចារ្យ **ហែម-ចៀវ**, លោកគ្រូអាចារ្យ **ប៉ាង-ខាត់**, លោកគ្រូអាចារ្យ **ស៊ូ-ហាយ**, លោកគ្រូអាចារ្យ **ខៀវ-ជុំ**, លោកគ្រូអាចារ្យ **អ៊ុក-ជា** ។

ក្រុមអ្នកបដិវត្តន៍ដែលមានព្រះសង្ឃបានចូលរួមផង បានធ្វើសកម្មភាពពេញទំហឹង ដោយមានលោកសឹង-ង៉ុកថាន់ជាមេ ។ កិច្ចការតស៊ូបានប្រព្រឹត្តទៅយ៉ាងសកម្ម ហើយប្រុងប្រយ័ត្នជាទីបំផុត ។

នៅគ.ស.១៩៤០ បារាំងបានស៊ីញ៉េទំលាក់អាវុធជាមួយអាល្លឺម៉ង់ លោកសឹង-ង៉ុកថាន់ឃើញឱកាសល្អប្រសើរដូច្នោះ ក៏ប្រជុំសមាគមសិស្សចាស់នៃវិទ្យាល័យស៊ីសុវត្ថិ ធ្វើញត្តិទាមទារឯករាជ្យពីបារាំង ។

លុះដល់គ.ស.១៩៤៤, បារាំងបានចាប់អាចារ្យ **ហែម-ចៀវ**, សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ ។

រឿងនេះបានក្លាយជាព្រឹត្តិការណ៍មួយ ដែលធ្វើឲ្យមជ្ឈដ្ឋានព្រះសង្ឃជានិស្សិតនៃសាលាបាលីជាន់ខ្ពស់ និងវត្តនានាក្នុងក្រុងភ្នំពេញ មានការរំជើបរំជួលយ៉ាងខ្លាំង ។ បន្ទាប់មក លោក **នួន-ឌួង** ក៏ត្រូវបារាំងចាប់ខ្លួនទៀត ។

ដំណឹងស្តីពីការចាប់ខ្លួនលោកគ្រូអាចារ្យ **ហែម-ចៀវ** និងលោក **នួន-ឌួង** (ធ្វើការនៅក្រុមជំនុំព្រះត្រៃបិដក)ក៏ត្រូវបានលេចឮសុសសាយទៅដល់ទិសទីជិតឆ្ងាយក្នុងអាណាចក្រខ្មែរ ។

លោកសឹង-ង៉ុកថាញ់បានសំរេចថា ធ្វើបាតុកម្មនៅថ្ងៃទី២០ កក្កដា ១៩៤៤ ដើម្បីទាមទារឲ្យបារាំងដោះលែងលោកគ្រូអាចារ្យ **ហែម-ចៀវ** និងលោក **នួន-ឌួង** មកវិញ ។ នេះគឺជាមហាបាតុកម្មដែលមានជាលើកដំបូងក្នុងប្រវត្តិសាស្ត្រខ្មែរយើង ។

ប៉ុន្តែគួរឲ្យស្តាយណាស់ ! បាតុកម្មដ៏សំខាន់នេះឥតបានសំរេចសមតាមបំណងសោះព្រោះបារាំងនិងរាជវាំងដែលមាន **នរោត្តម-សីហនុ** ជាស្តេចសោយរាជ្យ បានឃុបឃិតគ្នាបង្ក្រាបបាតុករយ៉ាងចាស់ដៃ ។ លោកគ្រូអាចារ្យ **ហែម-ចៀវ** បារាំងមិនព្រមលែង ! ហើយឯករាជ្យក៏បារាំងមិនប្រគល់មកខ្មែរដែរ ព្រោះបារាំងមានបង្អែកលើស្តេចដែលជួយជាកម្លាំងក្នុងការបង្ក្រាបនេះ ។ ពេលនោះបារាំងបានប្រើបរិវារឲ្យដើរចាប់ព្រះសង្ឃ គ្រហស្ថ បាតុករណាដែលពួកវាថាជាមេនាំបះបោរ យកទៅដាក់គុករួចនិរទេសទៅកោះត្រឡាច ដែលនៅទីនោះ ទារុណកម្មដ៏ឧក្រិដ្ឋបានបណ្តាលឲ្យអ្នកស្នេហាជាតិត្រូវបាត់បង់ជីវិត ដូចលោកគ្រូអាចារ្យ **ហែម-ចៀវ** ជាដើម ។

លោកសឹង-ង៉ុកថាន់ក៏ត្រូវបារាំងរកចាប់ខ្លួន ។ លោកបានភៀសខ្លួនចូលទៅក្នុងខេត្តបាត់ដំបង ហើយធ្វើដំណើរទៅកាន់តីក្រុងបាងកកប្រទេសថៃ ដោយបានធ្វើការទាក់ទងនឹងកងកម្លាំងជប៉ុន ដែលតាំងមូលដ្ឋានទ័ពនៅក្នុងប្រទេសថៃក្នុងគ្រានោះ ។ ពួកជប៉ុនក៏បាននាំលោកទៅនៅប្រទេសជប៉ុន ។ ក្នុងឱកាសស្នាក់នៅប្រទេសជប៉ុន លោកសឹង-ង៉ុកថាន់បានបន្តការទាក់ទងជាមួយក្រុមអ្នកបដិវត្តន៍ជប៉ុនបូព៌ាអាស៊ីអស់រយៈពេល ២ឆ្នាំ ។

នៅថ្ងៃទី៩ មីនា ១៩៤៥ កងកម្លាំងជប៉ុនចាប់អាជ្ញាធរបារាំងនៅប្រទេសវៀតណាម-កម្ពុជា-លាវ, ទុកសន្ធិសញ្ញាបារាំង-យៀកណាម-ខ្មែរ-លាវជាមោឃៈ ហើយក៏តាំងប្រកាសឯករាជ្យ ។

នៅខែឧសភា លោកសឹង-ង៉ុកថាន់បានវិលត្រឡប់បីប្រទេសជប៉ុនមកកាន់មាតុភូមិជាទីស្នេហាវិញ ហើយនៅថ្ងៃទី១មិថុនា១៩៤៥ លោកបានទទួលតំណែងជាទេសរដ្ឋមន្ត្រីទទួលបន្ទុកតាងប្រទេស ។ លុះដល់ថ្ងៃទី១៤ ខែសីហា ក្នុងឆ្នាំនោះ លោកបានឡើងធ្វើជានាយករដ្ឋមន្ត្រី ។ ប៉ុន្តែមកដល់ថ្ងៃទី១៦ ខែតុលា គ.ស.១៩៤៥ បារាំងចូលមកឥណ្ឌូចិនវិញ មកជាមួយនិងកងទ័ពសម្ពន្ធមិត្រ បានធ្វើរដ្ឋប្រហាររំលំ ហើយចាប់យក

លោកទៅឃុំនៅក្រុងព្រៃនគរ ។ តមកបារាំងនាំលោកទៅបង្ខាំងឯស្រុកបារាំង ។ ក្នុងឱកាសត្រូវគេបង្ខាំងនៅស្រុកបារាំងនោះ លោកបានបន្តវិជ្ជារហូតដល់បានប្រឡងជាប់បរិញ្ញាប័ត្រខាងច្បាប់ ។

ថ្ងៃទី២៩ ខែតុលា គ.ស.១៩៥១ បារាំងបានប្រគល់សេរីភាពដល់លោកវិញ ហើយគេបញ្ជូនឲ្យលោកអញ្ជើញមកកាន់ក្រុងភ្នំពេញ ។ មកដល់មាតុប្រទេសហើយ លោកបានធ្វើកាសែតមួយទៀតឈ្មោះ «**ខ្មែរក្រោក**» ពន្យល់ប្រាប់រាស្ត្រខ្មែរឲ្យដឹង ខ្មែរមិនទាន់បានឯករាជ្យទេ ទើបសារពត៌មានរបស់លោកត្រូវគេបិទ នៅជិតដំណាច់ខែកុម្ភៈហើយ ពួករាជវាំងនិងបារាំងក៏តាំងឃុបឃិតគ្នាគិតចាប់លោកម្តងទៀត ។ លោកសឺង ង៉ុកថាន់ដឹងខ្លួន ក៏ភៀសចេញទៅភ្នំដងរែក បង្កើតរណសិរ្សតស៊ូមួយឈ្មោះ «**ចលនាឥស្សរៈរួមខ្មែរ**» បំរើជាតិប្រកាសប្រាប់ពិភពលោកឲ្យដឹងថា ខ្មែរមិនទាន់បានឯករាជ្យនៅឡើយទេ ។ នៅថ្ងៃទី៩ ខែមីនា គ.ស១៩៥២ ហើយប្រមូលទ័ពឥស្សរៈវាយបារាំងទាមទារឯករាជ្យបរិបូណ៌ ។


ស្តេចសីហនុចេញប្រពាតព្រៃ

ថ្ងៃទី២០ ខែកក្កដា គ.ស.១៩៥៤ សន្និសិទក្រុងហ្សឺណែវប្រកាសប្រគល់ឯករាជ្យដល់ប្រទេសទាំងបួននៅឥណ្ឌូចិនគឺ វៀតណាមខាងត្បូង-វៀតណាមខាងជើង លាវ និងខ្មែរ ។ លោកសឺង-ង៉ុកថាន់បំរុងចូលរួមក្នុងមហាសង្គមជាតិដែរ ប៉ុន្តែស្តេចសីហនុទំនាស់មិនឲ្យចូល ។ តពីនោះមកស្តេចសីហនុធ្វើនយោបាយប្រជាភិថុតិ កាន់អំណាចផ្តាច់ការ ដណ្តើមអំណាចបីរាស្ត្រ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងធ្វើនយោបាយលំអៀងទៅរកលោកកុម្មុយនិស្ត ដោយបានបើកឲ្យយួនខាងជើងមកតាំងមូលដ្ឋានទ័ពនៅតាមបណ្តោយជាយដែនខ្មែរ-យៀកណាម សំរាប់ធ្វើសង្គ្រាមទៅវាយប្រហារប្រទេសវៀតណាមនិងថៃ ដែលជាប្រទេសបិតនៅជាប់ជញ្ជាំងផ្ទះនឹងខ្មែរ ។ រឿងនេះជាគ្រោះថ្នាក់ដល់ស្លាប់ជាតិបាត់ប្រទេស ព្រោះថ្ងៃណាមួយ វៀតណាមនិងថៃ ព្រមទាំងបក្សសម្ពន្ធយោធាការពារអាស៊ីអាគ្នេយ៍ គេនឹងលើកសកលយោធាមកបង្ក្រាបកុម្មុយនិស្ត ដែលជ្រកនៅប្រទេសកម្ពុជានេះ ។ ដូច្នេះប្រទេសកម្ពុជានឹងក្លាយទៅជាទីលានប្រយុទ្ធរបស់កងកម្លាំងមហាអំណាចទាំងពីរគឺ លោកសេរីនិងលោកកុម្មុយនិស្ត វាយប្រហារគ្នានៅលើទឹកដីយើង ធ្វើឲ្យប្រទេសខ្មែរវិនាសបាត់បង់ភោគទ្រព្យស្លាប់ជាតិ បាត់រូបភាពពីផែនទីលោកតែម្តង ។

ម៉្យាងទៀតនយោបាយអត្តឃាតរបស់សីហនុនេះនឹងនាំមកនូវគ្រោះភ័យអន្តរាយដល់អាយុជីវិតរបស់អានីតិជនខ្មែរ ដែលរស់នៅក្នុងប្រទេ-សវៀតណាមខាងត្បូងនិងប្រទេសថៃ ដែលពេលនោះកំពុងតស៊ូពង្រីកវប្បធម៌ អារ្យធម៌របស់ខ្លួនផង ។

## លោកសឺង-ង៉ុកថាន់
## បង្កើតចលនាខ្មែរសេរី

គ.ស.១៩៥៧, លោកសឺង-ង៉ុកថាន់បានចូលទៅប្រទេសវៀតណាមខាងត្បូង តាំងទីលំនៅៗភូមិធំ សង្កាត់ឡុក-និញ ខេត្តគគីរ (ខេត្តបិញឡុង) ដែលមានសហការី៤-៥នាក់នៅជាមួយ កាប់ឆ្ការព្រៃធ្វើចំការ ដាំចេក ដូង ស្វាយ ក្រូច ម្នាស់ ខ្នុរ ទៀប ។ល។

មកដល់ថ្ងៃទី១៦ តុលា ១៩៥៨ លោកបានបង្កើតចលនាខ្មែរសេរី ដែលពេលនោះមានសមាជិក១៤០នាក់ ធ្វើការកាប់ឆ្ការដីនិងរៀននយោបាយ ។ បន្ទាប់មក បានបង្កើតមូលដ្ឋានទីពីរហៅថា មូលដ្ឋានខូវណាម សំរាប់រៀនវិជ្ជាយុទ្ធសាស្ត្រ ចារកិច្ច ឃោសនាសេដ្ឋកិច្ចនយោបាយ ។

សូមបញ្ជាក់ថា ៖ មូលដ្ឋាននេះចម្ងាយពីមូលដ្ឋានភូមិធំប្រហែល១០ គ.ម. នៅខាងទិសពាព្យ ។ បានជាហៅថា ខូវណាម ដូច្នេះ ព្រោះនៅពេលហាត់រៀនវិជ្ជាយោធាចប់ភ្លាម មានមិត្តម្នាក់ឈ្មោះ ខូវ-ណាម បាត់បង់ជីវិតដោយជម្ងឺគ្រុនចាញ់ ។

លោកសឺង-ង៉ុកថាន់ក៏ឲ្យឈ្មោះយុវជនជំនាន់នោះថា សិស្សជំនាន់ខូវណាម ហើយឲ្យឈ្មោះមូលដ្ឋាននោះថា ខូវណាម ដូចគ្នា ។

តមក, យើងបានបង្កើតមូលដ្ឋានមួយទៀតសំរាប់ហ្វឹកហាត់វិជ្ជាចារកិច្ច ឃោសនា អប់រំបណ្តុះស្នូល នៅទីក្រុងព្រៃនគរតែម្តង ។ គឺមូលដ្ឋានគីម-សេដ្ឋា មានសិស្ស៥០នាក់ហាត់រៀន ដោយក្នុងចំណោមនោះមាននារីម្នាក់ផង ។ នៅក្នុងពេលកំពុងធ្វើសកម្មភាពខាងវិទ្យុ សិស្សនារីម្នាក់ឈ្មោះគីម-សេដ្ឋា ហៅគីម-អាន់ បានបាត់បង់ជីវិតដោយជម្ងឺពិស ។

លោកសឺង-ង៉ុកថាន់ជាប្រមុខចលនាក៏បានសំរេចឲ្យដាក់ឈ្មោះសិស្សជំនាន់គីម-សេដ្ឋា, ទាំងមូលដ្ឋាននេះក៏ប្រតិស្ថនាមថា មូលដ្ឋានគីម-សេដ្ឋាដែរ ។

សូមបញ្ជាក់ថា គីម-សេដ្ឋា ជាមូលដ្ឋានធ្វើសង្គ្រាមនយោបាយបានបញ្ជាបុគ្គលិក ឲ្យទៅបន្តុះស្នូលនៅគ្រប់ខេត្តទាំងអស់ក្នុងរដ្ឋវៀតណាម និងតាមខេត្តដែលស្ថិតនៅជាប់ជាយដែនខ្មែរ-យួន ។

ចលនាខ្មែរសេរី មានសកម្មភាពរីករហ័សណាស់ ដោយបានផ្សព្វផ្សាយសកម្មភាពខ្លួនពាសពេញសាធារណរដ្ឋវៀតណាម ឆ្លងចូលទៅដល់ប្រទេសកម្ពុជាទៀត ទើបបានជាមានមិត្តមួយក្រុម ភៀសចេញពីប្រទេសកម្ពុជាចូលមកប្រទេសវៀតណាម រួមធ្វើសហការជាមួយ ដោយជួយអប់រំមិត្តថ្មីៗឯទៀត ពីវិជ្ជាភូមិសាស្ត្រ ប្រវត្តិសាស្ត្រ ប្រវត្តិតស៊ូ ។ល។

## ការតស៊ូរបស់ចលនាខ្មែរសេរី

លុះដល់គ.ស.១៩៥៩ ចលនាខ្មែរសេរីបានបង្កើតមូលដ្ឋានមួយទៀតនៅខេត្តនរលក្ខណ (ដាកឡាក) ហៅថាមូលដ្ឋានព្យ៉សានទិស សំរាប់ធ្វើការទាក់ទងចូលមកក្នុងខេត្តរតនគិរី និងមណ្ឌលគិរី ។

កងកម្លាំងខ្មែរសេរីបានចេញពីមូលដ្ឋាននេះ ចូលមកព្រមានស្តេចសីហនុ កាលពីគ.ស.១៩៦០... ព្រោះដោយហេតុថា ចលនាខ្មែរសេរីដែលបានពន្យល់នេះតាមវិទ្យុសម្លេងចលនាខ្មែរសេរី អស់រយៈពេលជាងមួយឆ្នាំហើយនោះ មិនបានផលសោះ ។ ពេលនោះស្តេចសីហនុបែរជាធ្វើសន្និសិទនៃប្រជារាស្ត្រឥណ្ឌូចិន បើកវេទិកាប្រជាពលរដ្ឋប្រឆាំងតបទៅចលនាខ្មែរសេរីវិញផង ។

ក៏ប៉ុន្តែលុះដល់ឃើញស្តេចសីហនុងប់ងល់ក្នុងអំណាច ហ៊ានរុញកូនខ្មែរឲ្យទៅប្រយុទ្ធ ដើម្បីខ្លួនសីហនុផ្ទាល់ដូច្នេះ កងកម្លាំងខ្មែរសេរីក៏ដកថយទៅវិញ ដើម្បីជៀសវាងការបង្ហូរឈាមរវាងខ្មែរនិងខ្មែរ ។ ចលនាខ្មែរសេរីក៏ចាប់ងាកទៅធ្វើសកម្មភាពផ្សេងៗវិញ មានវិធានការអប់រំស្ងាត់ៗ បណ្តុះស្នូលនៅតាមខេត្តនិងរដ្ឋធានី ដើម្បីពន្យល់អំពីកំហុសនយោបាយ និងការប៉ុនប៉ងលេបទឹកដីខ្មែរ ដែលយួនយៀកកុងយួនខាងជើងធ្វើផែនការសម្ងាត់ ប្រទាក់ក្រឡាពីងពាង តាំងពីរដ្ឋធានីភ្នំពេញរហូតដល់ខេត្តទាំងអស់របស់ខ្មែរ រង់ចាំតែឱកាសល្អ វានឹងធ្វើរដ្ឋប្រហាររំលំស្តេច

សីហនុ សម្លាប់វរជនខ្មែរស្នេហាជាតិទាំងអស់តែម្តង ដូចជាពួកកុម្មុយនិស្តអន្តរជាតិតែងធ្លាប់ធ្វើការរំលាយជនជាតិតូចៗនៅអឺរ៉ុបដូច្នោះ ។

ប្រសិនបើពួកវៀតកុង-យួនខាងជើងធ្វើរដ្ឋប្រហារបានសំរេច អារ្យធម៌ខ្មែរនឹងវិនាសសូន្យអស់, ជាតិខ្មែរឈ្មោះថាស្លាប់ ទឹកដីខ្មែររលាយបាត់បង់ពីផែនទីសកលលោក ។ ឯខ្មែរដែលរស់នៅក្នុងវៀតណាមខាងត្បូងនិងថៃ ក៏អស់មាតុភូមិដូចជាសាសន៍ចាមទៅតាមនោះដែរ ។ ម៉្លោះហើយការតស៊ូរបស់បងប្អូនខ្មែរនៅវៀតណាមខាងត្បូង នឹងទៅជាឥតន័យ ព្រះពុទ្ធសាសនាខ្មែរក៏សាបសូន្យ វត្តខ្មែរទាំង៤៧៧ត្រូវផ្លាស់រូបទៅជាពុទ្ធសាសនាមហាយាន ឬទៅជាវត្តកៅដាយ ដូចនៅខេត្តរោងដំរីសព្វថ្ងៃនេះដូច្នោះ ។

ការតស៊ូរបស់ចលនាធ្វើទៅតាមផ្លូវអដ្ឋង្គិកមគ្គរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ គឺយើងដើរមាគ៌ាកណ្តាលមិនតឹងពេកមិនធូរពេក យោលទៅតាមស្ថានការណ៍នយោបាយសកលលោកផង តាមស្ថានការណ៍នយោបាយប្រទេសយើងផង ។

យើងបានសំរេចចិត្ត បញ្ជូនអ្នកស្នងការនយោបាយម្នាក់ឈ្មោះព្រាប-អ៊ិន ឲ្យមកពន្យល់ស្តេចសីហនុ ឲ្យយល់ពីគ្រោះថ្នាក់ស្លាប់ប្រទេសជាតិ និងឲ្យរួបរួមដោះស្រាយបញ្ហាខ្មែរ តាមផ្លូវចរចាគ្នាក្នុងឋានៈជាបងប្អូន ។ ប៉ុន្តែស្តេចសីហនុបែរច្រឡោតខឹង ចាប់យកព្រាប-អ៊ិនទៅប្រហារជីវិតដោយឥតជំនុំជំរះសោះឡើយ ។

( <u>កំណត់</u> ៖ ស្តេចសីហនុមិនព្រមបោះបង់ចោលទម្លាប់មួយ គឺច្រណែនឈ្នានិសអ្នកដទៃ មកពីគេមានគំនិតស្នេហាជាតិលើសខ្លួន ចេះដឹងជាងខ្លួន និងជាពិសេសនោះ ខ្លាចមិនបានធ្វើ<ធំ>លើគេ ) ។

(នៅមានត)

អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# សឺង-ង៉ុកថាន់

## វគ្គមានកងកម្លាំងពិសេសខ្មែរ

### សកម្មភាពលោកសឺង-ង៉ុកថាន់ ពីឆ្នាំ១៩៣០-១៩៧០

ដកស្រង់ចេញពីសៀវភៅរបស់លោក ថាច់-ខេមរិន្ទ

តមកពីលេខមុន...

### ការបង្កើតកងកម្លាំងពិសេសខ្មែរ



លោកសឺង-ង៉ុកថាន់
(គូរដោយអ៊ឹង-ប៊ុនហ៊ាង-ឆ្នាំ១៩៧២)
ក្នុងកាសែត<នគរធំ>

ដោយអស់សង្ឃឹមថា នឹងដោះស្រាយបញ្ហាខ្មែរតាមផ្លូវសន្តិវិធី ទើបលោកសឺង-ង៉ុកថាន់សំរេចចិត្តបង្កើតកងកម្លាំងពិសេសខ្មែរនៅថ្ងៃ១៥ ខែធ្នូ គ.ស.១៩៦៣ នៅមណ្ឌលឡុកនិញជាដំបូងហើយតាំងជាមូលដ្ឋានវាយខ្សែតាមបណ្តោយជាយដែនវៀតណាម-ខ្មែរ តាំងពីមូលដ្ឋានវាលកក់ ភូមិទ្រាំង ត្រើយខាងត្បូង ខេត្តមាត់ជ្រូក មកដល់កំពង់ទូក ឡងយុក ខេត្តឪឡែង (កៀងជុង), ស្វាច់-លឿង, ទន្លេចាម, គូទ្រាំង, ត្រពាំងរបង, ស្ទឹងថ្ម, ភ្នំតាកខ្មៅ, ខេត្តពោងដីរ, តាទៀក, ភូមិធំ, ឡុកនិញ, ដីក្រហមទប់, ប៊ុយដួច, ទំនាប់បុយ, យ៉ាម៉ប់ អណ្តូងស្វាយ, ដូច-ស្វាយ, ត្រាំខ្នា, មុយណា, ខ្ទង, ខេត្តព្រះបាទជាន់ទុក (គៀកឡុង), ពន្លឺក, ឱកឡឹប ក្នុងខេត្តទឹកផុស (ក្វាងឌឹក), ទាន់ហាន់ និងបន្ទាយប្រាំង, បុយ-ប្រាង ក្នុងខេត្តរល័ក្ខណា (ដាឡាត់) ។

កងកម្លាំងពិសេសខ្មែរនេះធ្វើការជាមួយនិងកងកម្លាំងសម្ពន្ធមិត្តសំរាប់ការពារជាយដែន រង់ចាំមើលជើងការប្រសិនបើយួនខាងជើងនិងវៀតកុងធ្វើរដ្ឋប្រហាររំលំស្តេចសីហនុ លេបទឹកដីខ្មែរតាមគោលការណ៍សម្ងាត់របស់ពួកវាមែន យើងនឹងបរទ័ពចូលមករំដោះមាតុភូមិយើងពីខ្មាំងឈ្លានពានឲ្យខាងតែបាន ។ ហេតុនេះ វៀតណាមហើយពួកយើងថា កងកម្លាំងពិសេស (ឡឹកលឿងដាក់បៀក) មានទីប្រឹក្សាវៀតណាមនិងអាមេរិកាំងនៅជាមួយនឹងយើង មិនមែនជាទាហានរដ្ឋការវៀតណាមទេ ព្រោះយើងគ្មានអត្តលេខ ដូចទាហានរៀបរយវៀតណាមនោះឡើយ ។

មកដល់ឆ្នាំ១៩៦៤ យើងចាប់ធ្វើសកម្មភាពនយោបាយខ្លាំងលើសមុន ដោយបានបង្កើតមូលដ្ឋានអប់រំវិជ្ជាបច្ចេកទេសឃោសនា ចារកិច្ចវិជ្ជាបណ្តុះស្នូលនៅមណ្ឌលបិញវ៉ា (ខេត្តឧកញ៉ាឌិន) និងតាមដានពិនិត្យសកម្មភាពពួកកុម្មុយនិស្ត នៅក្រុមខេត្តនិងរដ្ឋធានីភ្នំពេញ ព្រោះពេលនោះពួកវាចាប់ធ្វើសកម្មភាពបំផ្លាញសេដ្ឋកិច្ចខ្មែរ បង្កើតកងកម្លាំងយោធា មានទីតាំងមូលដ្ឋានទ័ព ស្តុកសម្ភារៈសឹកយ៉ាងសន្ធឹកសន្ធាប់នៅតាមជាយដែនខ្មែរ-យួន ពិសេសខេត្តខ្លះពួកវាហ៊ានបាញ់សម្លាប់ប្រជាពលរដ្ឋស្លូតត្រង់របស់យើងផង ដូចជានៅខេត្តស្វាយរៀង ផ្គាំរចេក មណ្ឌលគីរី រតនគីរីជាដើម ។ បុគ្គលិករបស់យើងធ្វើសកម្មភាពរហូតមក ហើយមិត្តខ្លះត្រូវស្តេចសីហនុសម្លាប់ ខ្លះទៀតជាប់គុករហូតដល់ថ្ងៃទី២ ខែមេសា គ.ស.១៩៧០ ទើបបានរដ្ឋាភិបាលស្រោចស្រង់ជាតិដោះលែងឲ្យមានសេរីភាព ។

ក្នុងការតស៊ូនេះ មិត្រយើងជាច្រើនដែលជាបុគ្គលិកសំខាន់ៗ បានបូជាជីវិតដោយពួកកុម្មុយនិស្តសម្លាប់ និងមិត្រខ្លះស្លាប់ដោយជម្ងឺនៅក្នុងសមរភូមិ ។ ខ្ញុំសូមជំរាបឈ្មោះមិត្រទាំងនោះដូចតទៅ ៖

១- អ្នកស្លាប់ដោយជម្ងឺ ៖

មិត្រ ខូវ-ណាម, គឹម-សេដ្ឋា, ញ៉ឹក-ញ៉ុក, ថាច់-សឹងសារី, គឹម-គង់, សឺង-យឹម, ថាច់-សាញ់ និងថាច់-រឹសោន ។ល។

២- អ្នកស្លាប់ដោយខ្មាំងលបសម្លាប់ ៖

មិត្រ ថាច់-តួង, ឡឹម-ឡឺ, ថាច់-ចាន់, សឹម-ហឹម, ថាច់-ញាណ, ថាច់-សូរី, ថាច់-ផាយ, ត្រឹង-ហឹម, អ្នកស្រីឡឹម-ឡឺ, គឹម-ចក់, គឹម-រៀង ។ល។

៣- អ្នកស្លាប់ក្នុងសមរភូមិ ៖

មិត្រ ថាច់-ស៊ួន, សឺង-សុវណ្ណ, ថាច់-ដួប, ថាច់-សិសា, ថាច់-សុខ, ថាច់-លឿង, ថាច់-ណោ, តោ-ត្រាន់, ថាច់-សឹម, ថាច់-ខ្លាំង, ថាច់-ស៊ីវត្ថា គឹម-វង់, ថាច់-សាយ, ថាច់-ញាន, គឹម-រ៉េន, វង់-សួត ។ល។

៤- អ្នកស្លាប់ដោយសីហនុសម្លាប់ ៖

មិត្រ ព្រាប-ឥន្ទ, ថាច់-យ៉ាង, សៅ-ង៉ុយ, ចៅ-បុរី, មធុរា, ថាច់-សីហា, ថាច់-ញើង, សាំង-សាវ៉ាត, សាម-សាម៉េត, អាចារ្យប្រុក, ទីវ-នឹងសាន ។ល។

៥ នាក់បាត់ខ្លួន ៖

មិត្រ ថាច់-សុផល និង ថាច់-រឿង ។ល។



បញ្ញវ័ន្តខ្មែរសេរីជាច្រើនរូប បានត្រូវស្តេចផ្តាច់ការសីហនុបញ្ជាសម្លាប់ ដោយគ្មានជំនុំជំរះទោស (នៅត្រពាំងក្រឡឹង-ខេត្តកំពង់ស្ពឺ)

ក្រៅពីនេះមានមិត្រយុទ្ធជនជាច្រើន ដែលខ្ញុំសូមអភ័យទោសដោយមិនបានរៀបរាប់ក្នុងទីនេះ ក៏ប៉ុន្តែទោះយ៉ាងនេះក្តី ឈ្មោះមិត្រទាំងនោះក៏មានចារទុកក្នុងបញ្ជីមាសដ៏កល់នៅចេតិយអនុស្សាវរីយ៍ក្នុងវត្តចន្ទរង្សី

ក្រុងព្រៃនគរដែរ ។

គ.ស.១៩៦៥ យើងបានបញ្ជូនយុទ្ធជនយើង ៣កងវរសេនាតូចទៅនៅបុរីរម្យខេត្តឧត្តរមានជ័យ២ កន្លែងធ្វើសកម្មភាពតាមជួរភ្នំដងរែក ជាយដែនខ្មែរ-ថៃ ។

គ.ស.១៩៦៩ រដ្ឋាភិបាលលោកឧត្តមសេនីយ៍លន់-នល់ឡើងកាន់ការរដ្ឋ ស្រោចស្រង់ប្រទេសជាតិ ដែលពេលនោះជិតលិចលង់ទៅបាតដាលទៅហើយ ។ មិត្ររបស់យើងដែលធ្វើសកម្មភាពនៅមូលដ្ឋានបស្ចឹមទិស ក៏នាំគ្នាចូលមកក្នុងមហាសង្គមជាតិវិញ ។ ឯមិត្រខ្លះក៏វិលទៅកាន់វៀតណាមខាងត្បូង ដើម្បីរៀបចំគ្គារង់ចាំពេលវេលា ។

គ.ស.១៩៧០ ថ្ងៃទី១៨ មិនា ព្រិត្តិការណ៍ប្រវត្តិសាស្រ្តផ្ទុះឡើងដោយសភាទាំងពីរនិងរដ្ឋាភិបាលស្រោចស្រង់ជាតិ សំរេចចិត្តជាឯកច្ឆន្ទ ទំលាក់ស្តេចសីហនុពីតំណែងប្រមុខរដ្ឋខ្មែរ ព្រោះស្តេចសីហនុក្បត់ប្រយោជន៍ប្រទេសជាតិ ក្បត់រាស្រ្តខ្មែរ គាំទ្រវៀតកុង-វៀតណាមខាងជើង ក្នុងពេលដែលរាស្រ្តខ្មែរ នៅខែត្រស្វាយរៀង រដ្ឋធានីភ្នំពេញ ធ្វើបាតុកម្មសូមកងទ័ពយួនខាងជើងដកថយពីប្រទេសខ្មែរ ឯសីហនុបែរជាចោទថា រាស្រ្តទាំងនេះក្បត់ជាតិទៅវិញ ។

ថ្ងៃទី២៨ ខែមិនា គ.ស.១៩៧០ យួនកុម្មុយនិស្តចាប់វាយប្រហារមកលើកងយោធពលខេមរជាតិ ដែលពេលនោះទ័ពយើងមានចំនួនតែជាង ៣ម៉ឺននាក់ប៉ុណ្ណោះ ។

រដ្ឋាភិបាលស្រោចស្រង់ជាតិដែលមានលោកឧត្តមសេនីយ៍លន់-នល់ជានាយក បានអំពាវនាវដល់ជនរួមជាតិខ្មែរទាំងអស់ ពិសេសខ្មែរស្នេហាជាតិដែលគេចខ្លួនចេញពីសង្គមជាតិ ឲ្យចូលមករួបរួមក្នុងមហាសង្គមជាតិ ព្រួតដៃគ្នាជាធ្លុងមួយនៅខាងក្រោយរដ្ឋាភិបាលស្រោចស្រង់ជាតិ ក្រោកឡើងប្រយុទ្ធប្តូរស្លាប់រស់ ចំពោះកងកម្លាំងទ័ពខ្មាំងឈ្លានពានយួនខាងជើង-យួនវៀតកុង ដេញកំចាត់ពួកវាឲ្យចេញផុតពីមាតុភូមិទឹកដីរបស់យើង ។

(<u>លី-ឡៀប</u> ៖ ស្តេចសីហនុជាអ្នកពន្យះកងទ័ពយៀកកុង-យៀកណាមខាងជើង ដែលមានចំនួនយ៉ាងច្រើនលើសលប់ ប្រកបដោយការពិសោធន៍សង្គ្រាមយូរឆ្នាំ និងប្រើអាវុធចិនដែលស្តេចសីហនុដដែលបានជួយជញ្ជូនតាមរយៈកំពង់ផែកំពង់សោម ឲ្យចូលមកផ្តិលផ្តាច់អាយុជីវិតខ្មែរនិងបំផ្លាញទ្រព្យសម្បត្តិខ្មែរសឹងពាយអស់ពីនគរ ។ ធ្វើដល់ម្លឹងទៅហើយ ស្តេចពាលនេះនៅតែមិនព្រមស្កប់ចិត្តទៀត... រហូតមកទល់ថ្ងៃនេះ ស្តេចសីហនុនៅតែទម្លាក់ទោស<វិនាសកម្មខ្មែរ> ទៅលើរបបសាធារណរដ្ឋខ្មែរ ទៅលើខ្មោចលោកលន់-នល់ ខ្មោចទ្រង់សិរិមតៈគ្មានឈប់ឈរទល់តែសោះ ។ អ្វីដែល<ចលនាខ្មែរសេរី>របស់លោកសឺង-ង៉ុកថាញ់ និងអ្វីដែល<របបសាធារណរដ្ឋខ្មែរ>របស់លោកលន់នល់-សិរិមតៈបានធ្វើគ្មានអ្វីក្រៅពីប្រឆាំងខ្មាំងឈ្លានពានទឹកដីខ្មែរនោះទេ ។ បើនៅពេលនោះស្តេចសីហនុ (ធ្វើខ្លួនដូចស្តេចបៅដាយរបស់យួន) គឺដកខ្លួនចេញឲ្យផុតពីនយោបាយខ្មែរ រួចទុករបបសាធារណរដ្ឋខ្មែរបំពេញតួនាទីរបស់ខ្លួនចប់ចុងចប់ដើម ពោលគឺព្រះអង្គមិនលោតទៅនៅខាងខ្មាំងទេ នោះវិនាសកម្មខ្មែរប្រហែលមិនធ្លាក់ដល់នរកដូច្នេះទេ ។ របបសាធារណរដ្ឋខ្មែរទី១ដ៏<ក្មេងខ្ចីនិងខ្វះការពិសោធន៍>នាពេលនោះ ត្រូវប្រឈមមុខសត្រូវជាច្រើន ៖ ស្តេចសីហនុ, យៀកកុង-យៀកណាមខាងជើង, ខ្មែរក្រហម និងសត្រូវផ្ទៃក្នុង ដែលភាគច្រើននោះជាពួកកូនចៅស្តេចសីហនុ ដែលលោកលន់-នល់អាណិតមេត្តាសន្តោសកាលពីដំបូងដៃ ដោយមិនចង់បង្ហូរឈាមខ្មែរគ្នាឯង ។ អំពើពុករលួយក៏ជាកត្តាមួយយ៉ាងធំមួយ នៃបរាជ័យផងដែរ ...ក៏ប៉ុន្តែអំពើពុករលួយ កើតឡើងនៅក្នុងរយៈពេលប្រទេសកើតសង្គ្រាម កើតកលយុទ្ធច្រួលច្របល់វឹកវរពេញនគរ រួចហើយត្រូវប្រឈមមុខនឹងវិទ្ធង្សនាកម្មគ្រប់បែបយ៉ាងពីខ្មាំង <ទាំងសេដ្ឋកិច្ចនិងសង្គមកិច្ច>ផងនោះ ...របបសាធារណរដ្ឋខ្មែរបានបាត់បង់នូវការគ្រប់គ្រងរបស់ខ្លួនអស់ទៅហើយ ។ គេមិនអាចថ្កោលទោសអំពើពុករលួយនៅក្នុងពេលស្រុកកើតសង្គ្រាមបានទេ ។ ស្រុកណាក៏ដូចស្រុកណាដែរ ពេលសង្គ្រាម គេមានបញ្ហារាប់រយដែលត្រូវដោះស្រាយ ។ នៅក្នុងករណីរបបសាធារណរដ្ឋខ្មែរ យើងត្រូវទប់ទល់នឹងសត្រូវដ៏ធំហួសម៉ាឌរបស់ខ្លួនផង និងត្រូវដោះស្រាយភាពអាសន្នសំរាប់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងភ្លើងសង្គ្រាមថែមទៀត ។ ក៏ប៉ុន្តែទោះបីអំពើពុករលួយបានកើតឡើងយ៉ាងណាក៏ដោយ ខ្ញុំពុំបានប្រទះឃើញមកដល់ថ្ងៃនេះ ពួកមេទាហានជំនាន់សាធារណរដ្ឋខ្មែរ ក្លាយទៅជា<មហាសេដ្ឋី>ណាម្នាក់សោះ ។ ភាគច្រើននោះ បានតែ<មួយគែ>និងគ្មានសល់អ្វីទេ ដែលខុសគ្នាពីសម័យរាជាណាចក្រទី២នេះឆ្ងាយណាស់ ដែលគេពុំអាចប្រៀបធៀបគ្នាទៅនឹងពួកមន្ត្រីខាងបក្សប្រជាជននិងបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិចបានសោះឡើយ ។ កំហុសរបបសាធារណរដ្ឋដែលស្តេចពាលសីហនុទទូចថ្កោលទោសគ្មានឈប់ឈរនោះ គឺគ្មានអ្វីក្រៅអំពី <ហ៊ានប្រឆាំង> មហាមិត្តរបស់ព្រះអង្គ ៖ យួនយៀកកុង-យៀកណាមខាងជើង និងពួកខ្មែរប្រហមឃាតកររាស្រ្តខ្មែរ ។ សូមសង្កេតមើលចុះ ! តើសព្វថ្ងៃស្តេចពាលនេះកំពុងកាន់ជើងខាងណាដែរ ? ហើយនិងដើម្បីអ្វីដែរ ? ) ។

មិត្រអាមេរិកាំងនិងវៀតណាមបានយល់ច្បាស់ នូវផលប្រយោជន៍របស់គេនិងផលប្រយោជន៍របស់យើងស្របគ្នា ដែលប្រឆាំងនឹងសត្រូវរួម គឺយួនកុម្មុយនិស្តដូចគ្នា ក៏យល់ព្រមឲ្យលោកសឺង-ង៉ុកថាន់ធ្វើការទាក់ទងមករដ្ឋាភិបាលយើង និងបញ្ជូនកងកម្លាំងពិសេសទាំងអស់ ឲ្យធ្វើមាតុភូមិនិវត្តន៍ តាមសេចក្តីស្នើសុំរបស់យើង ។ ចំណែកខាងមិត្រអាមេរិកាំង បានទាំងចងដៃឲ្យមិត្រយុទ្ធជនយើងម្នាក់នូវកាំភ្លើង១ដើម គ្រាប់រំសេវ សំលៀកបំពាក់ ព្រមទាំងគ្រឿងយោធបរិក្ខារផ្សេងៗ និងមានម៉ាស៊ីនទូរស័ព្ទជាច្រើនទៀត ដែលឥតគិតក្នុងជំនួយយោធាអាមេរិកាំងដែលផ្តល់ដល់រដ្ឋាភិបាលយើងឡើយ ។

នៅលើកទី១ មិត្ររបស់យើងចូលមកដល់មាតុភូមិនៅថ្ងៃទី៣០ ខែមេសា គ.ស.១៩៧០, លើកទី២មកដល់ថ្ងៃទី៣០ ខែមិថុនា គ.ស.១៩៧០, លើកទី៣ដល់ថ្ងៃទី១៩ ខែកញ្ញា គ.ស.១៩៧០ និងមានមកក្រោយជាបន្តទៀត ។

(<u>លី-ឡៀប</u> ៖ រាល់ពេលបងប្អូនខ្មែរកណ្តាលរបស់យើងមានបញ្ហា បងប្អូនខ្មែរក្រោមរបស់យើង តែងនាំគ្នាឡើងមកជួយជានិច្ច ។ នៅជំនាន់របបសាធារណរដ្ឋខ្មែរ បងប្អូនខ្មែរក្រោមជាច្រើនម៉ឺននាក់បានមកស្លាប់គរជើងគ្នានៅក្នុងកម្ពុជា ។ បើតាមការសង្កេតរបស់ខ្ញុំរៀងរហូតមក ខ្ញុំពុំដែលបានប្រទះឃើញបងប្អូនខ្មែរក្រោមទាំងអស់នោះ បានទទួលនូវការកោតសរសើរ ការដឹងគុណអ្វីសោះ... តែផ្ទុយទៅវិញត្រូវគេប្រមាថមើលងាយឬស្តោះទឹកមាត់ដាក់លើឆ្អឹងខ្មោចគ្នាថែមទៀត ។ វាជាការពិតប្រាកដណាស់ គឺចេញពី<ពួកជនសីហនុនិយម>... តែទោះបីយ៉ាងណាក៏ដោយគេគួរឈរលើភាពសមហេតុផល ហើយក្រឡេកមើលទៅ <ខ្លឹមសារ> និង<មូលហេតុ> ដែលឈាមទាំងអស់នោះបានហូរស្រោចស្រប់នៅលើទឹកដីខ្មែរយើងខ្លះផងទៅ (!!) បើមិនបានអរគុណទេ សូមមេត្តាកុំប្រមាថថែមទៀតអី ! ។ មានជនសីហនុខ្លះទៀតនោះ គេខ្វល់ពីឈ្មោះលោកសឺង-ង៉ុកថាន់ម្តេចម្តងសរសេរដាក់ស្រៈ< ឹ > ហើយម្តងសរសេរដាក់ស្រៈ< ុ > និងមានខ្លះទៀតចោទថា គាត់ជាជាតិ<ចិន-យួន>អីៗជាដើម ?! ) ។

ការធ្វើមាតុភូមិនិវត្តន៍ចូលមករួមរស់ក្នុងមហាសង្គមជាតិ យើងខ្ញុំអតីតចលនាខ្មែរសេរីស្ម័គ្រចិត្តរំលាយខ្លួនជាយុទ្ធជនម្នាក់ របស់កងយុទ្ធព

លខេមរជាតិ ដើម្បីរក្សាឯកភាពជាតិឲ្យមានជំហររឹងប៉ឹងមាំមួយខ្លាំងពូកែ សំរាប់ប្រយុទ្ធទល់នឹងខ្មាំងឈ្លានពានទឹកដី ប៉ុន្តែផ្នត់គំនិតរបស់យើងខ្ញុំនៅតែរក្សាវិន័យថ្លៃថ្នូរ ជាអ្នកបដិវត្តន៍ តាមលក្ខណៈគោលនយោបាយរបស់ចលនាខ្មែរសេរីគឺ សេរីភាព ប្រជាធិបតេយ្យ សង្គមខ្មែរថ្មី សន្តិភាព និង សុភមង្គល ។

យើងខ្ញុំសូមបញ្ជាក់ថា យើងខ្ញុំជាយុទ្ធជនខ្មែរមាតុភូមិនិវត្តន៍ ពុំមែនជា «ម៉ែកហ្វ៉ក» របស់អាមេរិកាំងទៀតឡើយ គ្រាន់តែជាទាហានបានហាត់រៀនវិជ្ជាយុទ្ធសាស្ត្រពីអាមេរិកាំង អំពីចំបាំងឆ្មក់ និងចំបាំងទ័ពព្រៃ ។

ករណិយកិច្ចរបស់យើងខ្ញុំ ក៏ដូចករណិយកិច្ចរបស់ពលរដ្ឋខ្មែរឯទៀតក្នុងបច្ចុប្បន្ននេះដែរ គឺយើងទាំងអស់គ្នាត្រូវព្រួតដៃគ្នា ស្មាទល់នឹងស្មា រួមសាមគ្គីផ្លូងមួយ ប្រយុទ្ធយ៉ាងក្លាហានអង់អាច ដេញកំចាត់ខ្មាំងឈ្លានពានទឹកដី រក្សានិងពង្រឹងសាធារណរដ្ឋខ្មែរឲ្យគង់វង់និងលូតលាស់ទៅអនាគត ។

លោកសឹង-ង៉ុកថាន់ក្នុងបច្ចុប្បន្ននេះ យើងខ្ញុំគោរពលោកក្នុងឋានៈជាគ្រូមគ្គុទ្ទេសក៍ និងជាអ្នកជួយកាប់ឆ្ការរៀបចំផ្លូវឲ្យ ហើយយើងខ្ញុំនាំគ្នាដើរមកមាតុភូមិរបស់ខ្លួន ក្នុងពេលដែលមាតុភូមិនេះរងគ្រោះដោយអំពើរាតត្បាតឈ្លានពាននៃជាតិសាសន៍ដទៃ គឺពួកយួនកុម្មុយនិស្ត ។ ដូច្នេះករណិយកិច្ចជាបឋមរបស់យើងខ្ញុំ ត្រូវធ្វើជាយុទ្ធជនដេញកំចាត់ខ្មាំង គោរពវិន័យរបស់កងយោធពលខេមរជាតិ ជាទាហានសកម្ម និងជាកងឯកភាពក្នុងបណ្តាកងឯកភាពទាំងអស់របស់កម្លាំងការពារសាធារណរដ្ឋខ្មែរ ។

ខាងមុខវិជ្ជាបច្ចេកទេសក្រៅពីវិជ្ជាយុទ្ធសាស្ត្រ យើងខ្ញុំមានមិត្តខ្លះជាអ្នកនិពន្ធ ជាឃោសនិក ជាអ្នកប្រែភាសាវៀតណាម-ខ្មែរ-អង់គ្លេស ជាបុគ្គលិកការិយាល័យជាអ្នកអប់រំជាអ្នកសហជីព ។ យើងខ្ញុំស្ម័គ្របំរើការតាមសមត្ថភាពរបស់ខ្លួន ។

ដោយវីរិយភាពឆ្លៀតសរសេរ និងសន្តានចិត្តដ៏បរិសុទ្ធ ស្នេហាជាតិមាតុភូមិ ស្មោះត្រង់និងមិត្ររួមឈាម សូមឲ្យជាតិ សាសនា សាធារណរដ្ឋខ្មែរ បានឈ្នះមារសត្រូវទមិឡជាស្ថាពរ ។

សូមឲ្យសាធារណរដ្ឋខ្មែរ រីកចំរើនលូតលាស់ គង់វង់ ស្ថិតស្ថេរ ចីរកាល...។

ភ្នំពេញ, ថ្ងៃទី១៧ ខែឧសភា គ.ស.១៩៧១

**ថាច់_ខេមរិន្ទ**

អង្គរបុរី

សម្លេងខ្មែរនៅបរទេស

# ឯកសារប្រវត្តិសាស្ត្រ



## កិច្ចសន្ទនារវាងលោកសឺង-ង៉ុកថាន់ និងសហការីពេលបង្កើតខ្មែរសេរី

ដកស្រង់ចេញពីព្រិត្តិប័ត្រ<មូលនិធិសឺង-ង៉ុកថាន់>
ចេញផ្សាយខែកញ្ញា ឆ្នាំ១៩៩១

នៅពេលដែលយើងខ្ញុំបានចេញពីភ្នំពេញ ទៅជួបនឹងលោកសឺង-ង៉ុកថាន់ យើងខ្ញុំបានសួរលោកថា ៖

**សំនួរ** ៖ ចុះលោកតាបង្កើតអង្គការខ្មែរសេរីធ្វើអ្វី ?

**ចម្លើយ** ៖ ខ្ញុំបានឃើញនូវគ្រោះថ្នាក់មហន្តរាយ ភ្លើងសង្គ្រាមចាប់ឆេះចូលមកដល់ផ្ទះខ្មែរ ។ ភ្លើងនេះមកពីសម្ដេចសីហនុ បានទទួលយកមកដាក់លើផ្ទះខ្មែរ ។ ដូច្នេះខ្ញុំជាពលរដ្ឋខ្មែរម្នាក់ ខ្ញុំមិនអាចឈរឱបដៃមើលអណ្ដាតភ្លើងសង្គ្រាមនេះឆេះមកលើផ្ទះខ្ញុំទេ ។ ពេលនេះបើបងប្អូនខ្មែរយើងដែលមានសមត្ថភាព មិនព្រមចេញមុខធ្វើការបំរើខ្មែរទេ រួចបណ្ដោយឲ្យជាតិនិងប្រជាជនទទួលនូវគ្រោះថ្នាក់នោះ ខ្ញុំម្នាក់ឯងក៏សុខចិត្តចេញមុខធ្វើការជួយសង្គ្រោះជាតិខ្មែរដែរ ។

<u>សូមបញ្ជាក់ថា</u> ៖ គ្រប់ចលនាតស៊ូដែលខ្ញុំបានបង្កើតឡើង លុះត្រាតែប្រទេសជាតិត្រូវការ ។ ស្រុកខ្មែរស្ថិតនៅជិតភាពអាសន្ន ។ បើប្រជាជននិងប្រទេសខ្មែរបានសុខសាន្តហើយ ខ្ញុំក៏មិនត្រូវការបង្កើតចលនាតស៊ូនេះដែរ ។

**សំនួរ** ៖ លោកតា, សម្ដេចសីហនុនិងវិទ្យុភ្នំពេញបានផ្សាយថា ស្រុកខ្មែរឥឡូវនេះមានសង់មហាវិទ្យាល័យ ផ្លូវថ្នល់ ស្ពាន និងមន្ទីរពេទ្យ ។ល។ ជាពិសេសស្រុកខ្មែរសំបូរសប្បាយណាស់ បើយើងខ្មែរសេរីចូលទៅ អាចធ្វើឲ្យប៉ះពាល់សេចក្ដីសុខសាន្តរបស់ប្រជាជនខ្មែរទេដឹង ?

**ចម្លើយ** ៖ បើធ្វើនយោបាយខុស ទោះបីជាខំកសាងជាងនេះមួយរយ ឬមួយពាន់ដង ឬក៏ច្រើនជាងនេះទៅទៀតក៏ដោយ, សាលារៀន ផ្លូវថ្នល់ស្ពាន និងមន្ទីរពេទ្យដែលសម្ដេចបានសង់នោះ ក៏នឹងវិនាសហិនហោចអស់ទៅវិញដែរ កុំថាឡើយត្រឹមសាលារៀន ឬស្ពានថ្នល់ប៉ុណ្ណោះ សូម្បីតែសម្បត្តិជាតិទឹកដីខ្មែរ រហូតដល់រាជបល្ល័ង្កទៀត ក៏នឹងត្រូវវិនាសហិនហោច គេចមិនផុតឡើយ ។ សម្ដេចសង្ឃជួន-ណាតបានជួយសម្ដែងសេចក្ដីបារម្ភរបស់ព្រះអង្គជាច្រើនដងចំពោះរឿងនេះ ដូចជាការព្រមានរបស់សម្ដេចជួន-ណាត ក្នុងឱកាសពិធីបុណ្យបញ្ចុះសីមាវត្តនាគព័ន្ធ (ទឹកល្អក់) ថា សម្ដេចនៅវ័យក្មេងពេក ខ្វះការពិសោធន៍ក្នុងរឿងនយោបាយ អាចនឹងនាំគ្រោះថ្នាក់ដល់ស្រុកខ្មែរទាំងមូល តែសម្ដេចសីហនុមិនបានស្ដាប់តាមឱវាទ របស់សម្ដេចសង្ឃជួន-ណាតឡើយ បែរជាខឹងខ្វាល់ ច្រឡោតឡើង បានត្មិះដៀលដល់រូបសម្ដេចសង្ឃជួន-ណាតវិញ យ៉ាងទ្រគោះតាមវិទ្យុ ដែលសម្ដេចសង្ឃជាគ្រូបង្រៀនផ្ទាល់របស់សម្ដេចសីហនុ ។ល។

**សំនួរ** ៖ លោកតា, សព្វថ្ងៃ, សម្ដេចនិងវិទ្យុភ្នំពេញបានជេរលោកតាថា ជាជនក្បត់ជាតិ ?

**ចម្លើយ** ៖ សម្ដេចសីហនុបានបញ្ជាឲ្យវិទ្យុភ្នំពេញជេរខ្ញុំ ការនេះមិនត្រឹមត្រូវស្របតាមច្បាប់ទេ ព្រោះថាមុននឹងចោទខ្ញុំថាក្បត់ជាតិនោះ លុះត្រាតែមានតុលាការធ្វើការវិនិច្ឆ័យ មិនមែនតាមតែការឈ្វេងយល់របស់សម្ដេចនោះទេ ។ បើលោកចង់ដឹងថាតើខ្ញុំ ឬសម្ដេចសីហនុជាជនក្បត់ជាតិនិងក្បត់រាស្ត្រនោះ សូមលោកចាំមើលប្រវត្តិសាស្ត្រលោក និងប្រវត្តិសាស្ត្រជាតិ គេនឹងសរសេរពីការពិត ហើយលោកនឹងបានយល់ច្បាស់ថា នរណាជាអ្នកក្បត់ជាតិខ្មែរ ។

**សំនួរ** ៖ លោកតា, គេថាលោកតាជាជនក្បត់ជាតិមែន ព្រោះលោកតាបានចូលរួមធ្វើការជាមួយជនក្បត់សម្ដេច ដូចជាលោកសមសារី, លោកដាប-ឈួន និងលោកសុន-សាក់ជាដើម ។

**ចម្លើយ** ៖ អំពើទាំងនេះមិនសរឲ្យឃើញថាខ្ញុំក្បត់ជាតិឯណា ? នេះសរឲ្យឃើញថា សម្ដេចសីហនុខ្វះសមត្ថភាពជាមេដឹកនាំ បានធ្វើឲ្យក្រុមសម្ដេចបែកបាក់គ្នាក្បត់គ្នាទេតើ ។ ហើយមានអស់លោកខ្លះបានមកសុំធ្វើការបំរើចលនាខ្មែរសេរីរបស់ខ្ញុំផង ។ ខ្ញុំយល់ឃើញថា គេធ្វើត្រូវចំពោះរឿងដែលគេមកសុំជួយធ្វើការឲ្យខ្មែរសេរី ។ ខ្ញុំមិនអាចឃាត់ឃាំងនរណាមួយ ដែលចង់ធ្វើនយោបាយប្រឆាំងនឹងសម្ដេចសីហនុឡើយ ព្រោះនយោបាយរបស់សម្ដេចជានយោបាយគ្មានគ្រឹះ បានបង្រៀនមនុស្សឲ្យគ្មានសេចក្ដីស្មោះត្រង់ជាមួយគ្នា ។ ដូច្នេះវារមែងតែងតែបង្កើតឲ្យមានគំនុំគុំគួន បែកបាក់រកល្បិចកលសម្លាប់តែគ្នាឯង ដើម្បីប្រាថ្នាគិតតែអំណាច បុណ្យស័ក្តិ មាសប្រាក់ផ្ទាល់ខ្លួនតែប៉ុណ្ណោះ ។

**សំនួរ** ៖ លោកតា, សម្ដេចសីហនុបានចោទលោកតា ជាអ្នកក្បត់រាជបល្ល័ង្កខ្មែរ ?

**ចម្លើយ** ៖ ចំពោះរាជបល្ល័ង្កខ្មែរ គឺសម្ដេចសីហនុនេះហើយដែលជាអ្នកក្បត់ ព្រោះទ្រង់បានធ្វើនយោបាយគ្មានគ្រឹះ យករបបរាជានិយមសក្តិភូមិ ទៅចូលរួមជាមួយប្លុកកុម្មុយនិស្ត ដែលជាគ្រោះថ្នាក់ដល់រាជបល្ល័ង្ករបស់ក្សត្រខ្មែរ ។

**សំនួរ** ៖ លោកតា, សម្តេចសីហនុបានចោទថា លោកតាប្រាថ្នាតំណែងប្រធានាធិបតីមែនឬ ?

**ចម្លើយ** ៖ ត្រង់តំណែងប្រធានាធិបតីឬប្រមុខរដ្ឋនោះ វាគ្មានសារៈសំខាន់អ្វីចំពោះខ្ញុំទេ ខ្មែរណា អ្នកណាគេក៏ធ្វើបានដែរ ឲ្យតែរកសេចក្តីសុខជូនប្រជារាស្ត្រ ឲ្យរាស្ត្រមានសិទ្ធិសេរីភាព ពោលគឺធ្វើឲ្យខ្មែររស់ ។ ចំពោះរូបខ្ញុំធ្វើអ្វីក៏បានដែរ ព្រោះពេលនេះសម្តេចសីហនុមើលមិនឃើញគ្រោះថ្នាក់ គ្មានអ្នកគេចេញមុខជួយដាស់តឿនសម្តេចសីហនុ បានជាខ្ញុំត្រូវចេញមុខ ជួយស្រែកប្រាប់បងប្អូនខ្មែរ នាំគ្នាជួយការពារឲ្យស្រុកខ្មែរយើងបានរស់រានគង់គេ ។

**សំនួរ** ៖ លោកតា, ស្រុកខ្មែរយើងគួរទុកឲ្យមានស្តេចសោយរាជ្យឬ?

**ចម្លើយ** ៖ ត្រង់នេះ... ខ្ញុំត្រូវធ្វើការគោរពទៅតាមលទ្ធិប្រជាធិបតេយ្យសេរី ពោលគឺធ្វើការបំរើឆន្ទៈប្រជារាស្ត្រ គឺប្រជារាស្ត្រជាអ្នកចាត់ចែង បើមតិប្រជារាស្ត្រខ្មែរភាគច្រើនគេត្រូវការទុក ខ្ញុំក៏គ្មានអ្វីជំទាស់ឡើយ ។

---

# បេសកកម្មខ្មែរសេរីស្វែងរកសន្តិភាពជាមួយសម្តេចសីហនុ

ក្រុមខ្មែរសេរីបានទទួលបេសកកម្មពីលោកសឺង-ង៉ុកថាន់ ឲ្យចូលទៅធ្វើការណែនាំពន្យល់ប្រជាជនខ្មែរ អំពីគ្រោះថ្នាក់នៃនយោបាយរបស់សម្តេចសីហនុ ដែលងាកទេរទៅរកកុម្មុយនិស្ត និងអំពីនយោបាយសេរីនិយមរបស់ខ្មែរសេរី ។ យើងត្រូវតែធ្វើនយោបាយសន្តិវិធីជាមួយបងប្អូនខ្មែរ លោកបានពន្យល់ថា ៖

« បើកាលណា យើងចូលទៅបានជួបប្រទះជាមួយទាហានក្តី ប្រជាជនខ្មែរក្តី យើងតោងតែព្យាយាមពន្យល់ទាហាន និងប្រជាជនខ្មែរឲ្យយល់ពីបេសកកម្ម និងនយោបាយរបស់ខ្មែរសេរីៗគ្មានបំណងនឹងធ្វើការបង្ហូរឈាមខ្មែរគ្នាឯងទេ គឺខ្មែរសេរីគ្រាន់តែសុំផ្លូវដើរចូលទៅកាន់ទីក្រុងភ្នំពេញ ប្រាប់អ្នកដឹកនាំនិងប្រជាជនខ្មែរ អំពីគ្រោះថ្នាក់របស់យួនកុម្មុយនិស្ត ហើយធ្វើឲ្យនយោបាយអព្យាក្រឹតពិតប្រាកដឡើងវិញ ដើម្បីរកសេចក្តីសុខសំរាប់ប្រទេសជាតិ និងប្រជាជនខ្មែរ ពេលខ្មែរបានសុខហើយ ខ្មែរសេរីនឹងឈប់ធ្វើសកម្មភាពទៀតហើយ ។

ប៉ុន្តែ បើសម្តេចនរោត្តម-សីហនុនៅតែធ្វើនយោបាយមានៈ បំពានទៅរកផ្លូវខុសនោះ យើងខ្មែរសេរីសូមធ្វើការប្រឆាំងនឹងនយោបាយរបស់ទ្រង់ ដើម្បីការពារជាតិ ប្រជាជន និងទឹកដីខ្មែរជាដាច់ខាត ៖

★ ខ្មែរសេរីយល់ថា អំពើដែលសម្តេចសីហនុអនុញ្ញាតឲ្យពួកយួនកុម្មុយនិស្តប្រើប្រាស់ទឹកដីខ្មែរ សំរាប់ធ្វើសង្គ្រាមជាមួយប្រទេសជិតខាង គឺហាក់ដូចជាសម្តេចសីហនុយកចោរមកចិញ្ចឹមនៅក្នុងផ្ទះ ។ ចោរនោះនឹងចេញពីផ្ទះយើង ទៅលួចអ្នកជិតខាងភូមិផងរបង់ជាមួយ ។ តែអ្នកជិតខាង គេមិនខឹងនឹងចោរនោះឡើយ គេច្បាស់ជាខឹងនឹងអ្នកចិញ្ចឹមចោរនោះជាមិនខាន ។ ម៉្យាងទៀតយួនកុម្មុយនិស្តដែលសម្តេចសីហនុជួយឲ្យរស់នៅលើទឹកដីខ្មែរ ក៏គ្មានចិត្តស្មោះត្រង់នឹងខ្មែរដែរ គេនឹងលួចខ្មែរហើយប្លន់យកទឹកដីខ្មែរយើងថែមទៀត ។

★ ចំពោះចំណងរវាងចិនកុម្មុយនិស្តជាមួយនិងសម្តេចសីហនុ លោកសឺង-ង៉ុកថាន់បានមានប្រសាសន៍ទៅកាន់ពួកយើងថា ៖

« សម្តេចសីហនុត្រូវតែហ៊ានប្រាប់ចិនដោយត្រង់ៗថា សូមចិនឈប់មកជួយខ្មែរទៅ ព្រោះការជួយខ្មែរដោយនាំចំបាំងចូលមកស្រុកខ្មែរនោះ ទុកដូចជាយកដុំភ្លើង មកដុតផ្ទះខ្មែរអញ្ចឹង ។ បើចិនចង់ជួយខ្មែរដោយស្មោះត្រង់ គឺចិនមិនត្រូវជួយខ្មែរ ហើយបណ្តាលឲ្យភ្លើងឆេះផ្ទះខ្មែរឡើយ ។ ចិនត្រូវជួយខ្មែរឲ្យស្របទៅតាមផលប្រយោជន៍ និងតាមឆន្ទៈរបស់ប្រជាជនខ្មែរ ដូចជាជួយធ្វើឲ្យមានសន្តិភាពដល់ខ្មែរ, ជួយរក្សាអព្យាក្រឹតពិតប្រាកដរបស់ខ្មែរ ។ល។ ចិនមិនត្រូវអូសទាញយកដីខ្មែរទៅធ្វើជាទីលានសមរភូមិ រវាងប្រទេសខ្មែរនិងប្រទេសជិតខាងឡើយ ។

<u>ការកត់សំគាល់</u> ៖ ហេតុដូច្នេះ ចំពោះខ្មែរសេរីដែលប្រឆាំងនឹងសម្តេចសីហនុនោះ មិនមែនជាជម្លោះប្រឆាំងនឹងនយោបាយអព្យាក្រឹតពិតប្រាកដទេ តែនេះជាជម្លោះប្រឆាំងនឹងនយោបាយអព្យាក្រឹតរបស់ទ្រង់ ដែលងាកទេរទៅរកកុម្មុយនិស្ត សុខចិត្តយកស្រុកខ្មែរទៅបំរើផលប្រយោជន៍យួនទេតើ ។

❑

ក្នុងគោលបំណងចង់ជៀសវាងប្រើកម្លាំងយោធា លោកសឺង-ង៉ុកថាន់បានចាត់វិធានការរកមធ្យោបាយធ្វើការចរចា ជាមួយសម្តេចសីហនុជាច្រើនលើក ។ លោកបានរៀបចំដាក់ភ្នាក់ងារខ្មែរសេរីនៅតាមជាយដែនខ្មែរ-យៀកណាម តាំងពីហាទៀងរហូតដល់ឡុកនិញ ។

★ លោកព្រាប-អ៊ិន, លោកព្រាប-អ៊ីន និងលោកសារុន នៅតំបន់ហាទៀងទល់មុខនឹងតាកែវ ។ លោកសារុន បានចូលទៅដល់ភ្នំពេញចំនួន៥ថ្ងៃ រួចបានត្រឡប់មកវិញ ។

★ លោកជី-ម៉ាន់ និងលោកស៊ិម-គិន នៅតំបន់ខេត្តពោងដឺរី ទល់មុខនឹងស្វាយរៀងនិងព្រៃវែង ។ លោកស៊ិម-គិនបានចូលទៅដល់ភ្នំពេញចំនួនមួយអាទិត្យ ដើម្បីពន្យល់ពីគ្រោះថ្នាក់ដល់ប្រទេសខ្មែរ រួចទើបត្រឡប់មកវិញ ។

★ លោកម៉ុក-យ៉ែម, លោកសារាយ-ផន និងលោកវ៉ាន-ឈួង នៅតំបន់ឡុកនិញ ទក់មុខកំពង់ចាម ស្នួល ក្រចេះ ។

★ ពន្យល់ខ្មែរពីគ្រោះថ្នាក់របស់យួនកុម្មុយនិស្តនៅក្នុងស្រុកខ្មែរ ។

★ ធ្វើការសម្ងាត់ទាក់ទងចរចាជាមួយសម្តេចសីហនុ សុំឲ្យទ្រង់ធ្វើការកែប្រែនយោបាយឈប់គាំទ្រយួនកុម្មុយនិស្ត ។

★ ធ្វើការស៊ើបអង្កេតតំបន់យួនកុម្មុយនិស្ត និងសកម្មភាពរបស់វានៅលើទឹកដីខ្មែរ ។

ប្រហែលបួន-ប្រាំខែ ក្រោយពេលយើងត្រឡប់ពីភ្នំពេញវិញ យើងបានទទួលពត៌មានខ្លះៗ និងវិទ្យុភ្នំពេញផ្សាយជាផ្លូវការថា សម្តេចសីហនុហៅខ្មែរសេរីដើម្បីធ្វើការចរចាដោះស្រាយរឿងនយោបាយស្រុកខ្មែរ។ ពេលនោះលោកសឺង-ង៉ុកថាន់ក៏បានប្រមូលមេខ្មែរៗសេរីមកប្រជុំ រួចបានយកបញ្ហាចរចានេះមកជជែក ។ អង្គប្រជុំបានសំរេចថា ត្រូវតែហ៊ានធ្វើការចរចានេះ បើសិនជាការចរចានេះ បានសំរេចដូចបំណងនោះមែនទឹកដីខ្មែរក៏បានគង់វង្ស ប្រជាជនខ្មែរក៏បានចៀសផុតពីគ្រោះថ្នាក់ភ្លើងសង្គ្រាម ។

ពេលនោះលោកសឺង-ង៉ុកថាន់បានសួរទៅលោកទិត-អួនថា ៖

«អួនឯងហ៊ានទៅធ្វើការចរចាជាមួយសម្តេចសីហនុទេ ព្រោះសម្តេចសីហនុត្រូវការសំរួលនយោបាយជាមួយនឹងយើងហើយ» ។

ប៉ុន្តែលោកព្រាប-អ៊ិន បានឆ្លើយតបនឹងសំនួររបស់លោកសឺង-ង៉ុកថាន់ ជំនួសលោកអួនថា ៖

«ខ្ញុំស្ម័គ្រចិត្តទៅធ្វើការចរចានេះ» ។

បេសកជនព្រាប-អ៊ិន ជាអ្នកនាំពាក្យរបស់លោកសឺង-ង៉ុកថាន់ ហ៊ានសំរេចចិត្តចេញទៅធ្វើការចរចា ដោយមិនគិតគ្រោះថ្នាក់ផ្ទាល់ខ្លួនព្រោះយល់ថាបេសកកម្មនេះមានសារៈសំខាន់ចំពោះខ្មែរ ។ ហើយបើបានសំរេចបេសកកម្មនេះ អាចធ្វើឲ្យខ្មែរឆ្លងផុតពីគ្រោះអន្តរាយ បាត់បង់ទឹកដីដូចយើងបានឃើញសព្វថ្ងៃនេះ ។ ក៏ប៉ុន្តែ សម្តេចបែរជាក្បត់នឹងសំដីរប

ស់ទ្រង់ យកលោកព្រាប-អ៊ិនទៅសម្លាប់ចោល ដោយឥតមានទុកឱកាសឲ្យលោកព្រាប-អ៊ិនបញ្ចេញយោបល់ការពារខ្លួន សូម្បីតែមួយម៉ាត់ក៏គ្មានផង ។ ក្រោយពីសម្ដេចសម្លាប់លោកព្រាប-អ៊ិនយ៉ាងអយុត្តិធម៌មក បងប្អូនខ្មែរក៏បានជ្រាបស្រាប់ហើយ កាំភ្លើងខ្មែរសេរីក៏ចាប់ផ្ទុះឡើងនៅតាមជាយដែនខ្មែរ-យៀកណាម និងខ្មែរ-ថៃ (សូមមើលផែនទីភ្ជាប់មកជាមួយនេះ) ។ ឈាមខ្មែរចាប់ហូរឡើងវិញ ដោយធ្វើការចរចាជាមួយខ្មែរសេរី ។ ដូចបងប្អូនជ្រាបស្រាប់ហើយ ភ្លើងសង្គ្រាមតាមជាយដែនខ្មែរក៏រាលដាលចូលស្រុកខ្មែរកាន់តែជ្រៅ ។ យៀកកុងចូលមកនៅពាសពេញទឹកដីខ្មែរកាន់តែច្រើនឡើងៗ ធ្វើឲ្យប្រទេសខ្មែរមានវិបត្តិខាងសេដ្ឋកិច្ចនិងយោធាមិនចេះចប់ ។ ឧត្ដមសេនិយលន់-នល់បង្កើតរដ្ឋាភិបាលស្រោចស្រង់ជាតិ រួចបានបញ្ជាលោកវរៈសេនិយឯក ស៊ុន-ថៃ ទៅដេញយួនយៀកកុងចេញពីទឹកដីខ្មែរ នៅតាមតំបន់កំពង់ចាម ក្រចេះ និងស្ទឹងត្រែង ។ល។ ពួកយួនយៀកកុងនៅលើទឹកដីខ្មែរមិនព្រមចេញ រួចវាយករូបសម្ដេចសីហនុមកពាក់ ប្រាប់ថាសម្ដេចឲ្យដីវានៅ ។ លុះយួនយៀកកុងមិនចេញពីដីខ្មែរ និងមានបញ្ហាផ្ទៃក្នុងស្មុគស្មាញដោះស្រាយមិនរួច សម្ដេចសីហនុនៅមិនបានរកច្រកចេញទៅបរទេស ។ ឧត្ដមសេនិយលន់-នល់បានបង្កើតសាធារណរដ្ឋខ្មែរ និងបានទាំងពឹងខ្មែរសេរីឲ្យមកជួយដើម្បីដោះស្រាយបញ្ហាខ្មែរក៏មិនរួច ព្រោះទំនប់ទឹកវាបាក់មកហើយ ។ បន្ទាប់មក ចិននិងយួនបានរៀបចំផែនការបន្ថែម ដោយបញ្ចូលរូបខៀវ-សំផននិងប៉ុល-ពត មកបន្តផែនការនយោបាយខុសរបស់សម្ដេចសីហនុ បណ្ដាលឲ្យប្រជាជនខ្មែរស្លាប់មួយជាន់ទៀតអស់រាប់លាននាក់ នៅក្រោមព្រះនេត្ររបស់សម្ដេចសីហនុទៀតផង ។




ចុងបំផុត យួនយៀកកុងដែលសម្ដេចសីហនុធ្លាប់បានផ្ដល់ភស្តុភាឲ្យទឹកដីជ្រកកោន និងដើរកាត់ ។ល។ ក៏ចូលមកយកទឹកដីខ្មែរតែម្ដង ។ អ្វីៗទាំងអស់ដែលសម្ដេចសីហនុបានសាងសង់ ក៏ត្រូវវិនាសបាត់បង់ដូចលោកសឺង-ង៉ុកថាន់បានទាយទុក កាលពី៣៥ឆ្នាំមុនមែន ។ មិនត្រឹមតែប៉ុណ្ណោះទេ ទឹកដីខ្មែរក៏ត្រូវបាត់បង់ ប្រជាជនខ្មែរត្រូវវិនាសអន្តរាយយ៉ាងខ្លោចផ្សារជាទីបំផុត ។ « នេះមកតែពីសម្ដេចសីហនុធ្វើនយោបាយខុស» ព្រោះតែទ្រង់បដិសេធមតិប្រជារាស្ត្រ មានឱវាទសម្ដេចសង្ឃជួន-ណាត និងយោបល់របស់លោកសឺង-ង៉ុកថាន់ជាដើម ។៚